ព្រះរាជាណាចក្រកម្ពុជា

ទីស្ដីការគណៈរដ្ឋមន្ត្រី ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៤ សសរ

# សេចក្ដីសម្រេច

# ស្ដីពី

# និតិវិធី និងបែបបទនៃការរៀបចំអង្គប្រជុំអន្តរក្រសួង នៅទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- ផ្អែកលើតម្រូវការចាំបាច់ក្នុងការរៀបចំបែបបទពាក់ព័ន្ធនឹងអង្គប្រជុំអន្តរក្រសួង

# សម្រេច

**ប្រការ ១.-**

រាល់សំណុំឯកសារ ដែលក្រសួង ស្ថាប័នសាមីនីមួយៗ ស្នើសុំដាក់ឆ្លងអង្គប្រជុំអន្តរក្រសួង នៅទីស្ដីការគណៈរដ្ឋមន្ត្រី ទោះបីប្រភេទទូលាយក្ដី ឬ ចង្អៀតក្ដី ត្រូវបានបញ្ជូនទៅអគ្គលេខាធិការរាជរដ្ឋាភិបាល ដើម្បីរៀបចំចុះក្នុងបញ្ជីប្រតិទិននៃកិច្ចប្រជុំអន្តរក្រសួង។ អគ្គលេខាធិការរាជរដ្ឋាភិបាលត្រូវរៀបចំបញ្ជីប្រតិទិននៃកិច្ចប្រជុំអន្តរក្រសួង

តាមខ្លឹមសារ ដែលក្រសួង ស្ថាប័ននីមួយៗបានផ្ញើមកនោះឱ្យបានមុនមួយសប្តាហ៍ នៃថ្ងៃបើកអង្គប្រជុំ ដើម្បីសុំមតិសម្រេចពីប្រធានស្ថាប័ន។

**ប្រការ ២.–**

ប្រធានអង្គប្រជុំអន្តរក្រសួងទាំងពីរភេទ ទោះទូលាយ ឬ ចង្អៀតនោះ ត្រូវដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់ ឬ ដោយថ្នាក់ដឹកនាំនៃទីស្តីការគណៈរដ្ឋមន្ត្រី តាមការប្រគល់ភារកិច្ចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី លើប្រតិទិននៃកិច្ចប្រជុំអន្តរក្រសួង ប្រចាំសប្តាហ៍នីមួយៗ។ ក្នុងករណីមានជាប់កិច្ចរវល់ក្នុងភារៈកិច្ចផ្សេងចាំបាច់នោះ ថ្នាក់ដឹកនាំទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានឈ្មោះដឹកនាំអង្គប្រជុំក្នុងប្រតិទិនប្រចាំសប្តាហ៍ ត្រូវរាយការណ៍សុំយោបល់សម្រេចពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចាត់តាំងអ្នកដឹកនាំអង្គប្រជុំអន្តរប្រជុំក្រសួងជំនួស។

**ប្រការ ៣.–**

ប្រធានអង្គប្រជុំ ដែលត្រូវបានចាត់តាំងឱ្យដឹកនាំអង្គប្រជុំអន្តរក្រសួងនោះ មិនមានសិទ្ធិសម្រេចទេ តែមានភារកិច្ចសម្របសម្រួល ប្រមូលផ្តុំគំនិតពីគ្រប់ភាគី ដោយធ្វើសំយោគសរុបអំពីយោបល់ដែលបានឯកភាព និងចំណុចឬបញ្ហាដែលនៅសេសសល់ រួចធ្វើរបាយការណ៍អំពីលទ្ធផលដែលអង្គប្រជុំទាំងមូលបានឯកភាពសម្រេចនោះ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជ្រាប និងចាត់វិធានការបន្ត។

**ប្រការ ៤.–**

អគ្គលេខាធិការរាជរដ្ឋាភិបាល រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក ប្រធានគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការ ក្រុមប្រឹក្សា និងប្រធានអាជ្ញាធរដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល:**

- គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ